ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីអំពាវនាវ
# ស្តីពី
# ការរក្សាសុវត្ថិភាពក្នុងការធ្វើដំណើរវិលត្រឡប់របស់បងប្អូនពលករខ្មែរមកពីប្រទេសថៃ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនបងប្អូនពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ ជ្រាបថា ដើម្បីធានាសុវត្ថិភាព និងចៀសវាងគ្រោះថ្នាក់ដោយថាហេតុក្នុងពេលធ្វើដំណើរឆ្លងកាត់ច្រកព្រំដែនកម្ពុជា-ថៃ ក្រសួងសូមអំពាវនាវដល់បងប្អូនដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ សូមបន្តអត់ធ្មត់រក្សាភាពស្ងៀមស្ងាត់ និងស្នាក់នៅ និងធ្វើការនៅទីតាំងការងាររបស់ខ្លួនជាធម្មតា និងត្រូវចៀសវាងការជួបជុំ ឬធ្វើដំណើរវិលត្រឡប់មកកាន់ច្រកព្រំដែន រហូតដល់ស្ថានភាពវិលត្រឡប់មកជាប្រក្រតីឡើងវិញ។

ក្នុងករណីមានការគំរាមកំហែង ការបំភិតបំភ័យ ឬការបៀតបៀនណាមួយ សូមបងប្អូនទំនាក់ទំនងស្វែងរកការគាំពារសុវត្ថិភាព តាមរយៈអាសយដ្ឋាន និងលេខទូរសព្ទដូចខាងក្រោម៖

- **ស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងបាងកក** ទូរសព្ទលេខ៖ ០២ ៩៥៧ ៥៨៥១ / ០៩២ ៨០៥ ០៥៦១ និងស្ថានអគ្គកុងស៊ុលនៅខេត្តស្រះកែវ ទូរសព្ទលេខ៖ ០៨០ ៣៩៣ ៦៨៧៨ / ០៨៥ ០១២ ៣៦៦៨
- **អនុព័ន្ធការងារនៅទីក្រុងបាងកក** ទូរសព្ទលេខ៖ ០៩៤ ០៩២ ៥៩០៥ / ០៩៤ ៤១៦ ៥៥១៨/ ០៨៣ ៥៤៥ ៧៧៨៨ / ០៩២ ២៩៩ ០១៣៣ និង**អនុព័ន្ធការងារនៅខេត្តស្រះកែវ** ទូរសព្ទលេខ៖ ០៦២ ០៨៩ ៨៩១៨ / ០៨០ ៨១០ ៥៥០៥
- **អង្គការសហប្រជាជាតិ (UN)** ទូរសព្ទលេខ៖ ០២ ២៨៨ ១៨០៧, United Nations Building, 15th Floor, Rajdamnern Nok Avenue, Bangkok, Thailand
- **អង្គការអន្តរជាតិខាងការងារ (ILO)** ទូរសព្ទលេខ៖ ០២ ២៨៨ ១២៣៤, United Nations Building, Rajdamnern Nok Avenue, Bangkok, Thailand
- **អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)** ទូរសព្ទលេខ៖ ០២ ៣៤៣ ៩៣០០, United Nations Building, 18th Floor, Rajdamnern Nok Avenue, Bangkok, Thailand
- **មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ នៅទីក្រុងបាងកក** ទូរសព្ទលេខ៖ ០២ ៥១៣ ៩២៤២ / ០២ ៥១៣ ៨៩៥៩, **នៅខេត្តឈៀងម៉ៃ** ទូរសព្ទលេខ៖ ០៥៣ ៨១១ ២០២ / ០៥៣ ២៧១ ៥៥១ និង**នៅម៉េស៊ត** ទូរសព្ទលេខ៖ ០៥៥ ៥៣៥ ៩៩៤ / ០៥៥ ៥៣៦ ០១៥។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តតាមដានស្ថានការណ៍ដោយយកចិត្តទុកដាក់ និងសហការជាមួយអង្គការសហប្រជាជាតិ (UN), អង្គការអន្តរជាតិខាងការងារ (ILO), អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងភាគីពាក់ព័ន្ធ ដើម្បីធានាថាសិទ្ធិ និងសុវត្ថិភាពរបស់បងប្អូនពលករខ្មែរ ត្រូវបានគាំពារស្របតាមច្បាប់អន្តរជាតិ។

ថ្ងៃសៅរ៍ ១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥